ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងមហាផ្ទៃ
អគ្គនាយកដ្ឋានរដ្ឋបាល

លេខ : ១២៤៦ អរប

ថ្ងៃច័ន្ទ ១០កើត ខែចេត្រ ឆ្នាំរកា នព្វស័ក ព.ស.២៥៦១
រាជធានីភ្នំពេញ ថ្ងៃទី២៦ ខែមីនា ឆ្នាំ២០១៨

## ជម្រាបជូន

**ឯកឧត្តម លោកជំទាវ អភិបាល នៃគណៈអភិបាលរាជធានី ខេត្ត**

**កម្មវត្ថុ** : ស្តីពីការផ្សព្វផ្សាយការប្រឡងជ្រើសរើសមន្ត្រីរាជការ សិស្ស និស្សិតអាហារូបករណ៍ទៅសិក្សានៅបរទេសសម្រាប់ឆ្នាំសិក្សា២០១៨។

**យោង** : លិខិតលេខ ០៧ អយក.សណន ចុះថ្ងៃសុក្រ ២កើត ខែផល្គុន ឆ្នាំរកា នព្វស័ក ព.ស.២៥៦១ ត្រូវនឹងថ្ងៃទី១៦ ខែកុម្ភៈ ឆ្នាំ២០១៨ របស់ក្រសួងអប់រំ យុវជន និងកីឡា។

សេចក្តីដូចមានចែងក្នុងកម្មវត្ថុ និងយោងខាងលើ ខ្ញុំសូមជម្រាប **ឯកឧត្តម លោកជំទាវ** មេត្តាជ្រាបថា ក្រសួងអប់រំ យុវជន និងកីឡា សូមធ្វើការផ្សព្វផ្សាយសេចក្តីជូនដំណឹងស្តីពីការប្រឡងជ្រើសរើសមន្ត្រីរាជការ សិស្ស និស្សិតអាហារូបករណ៍ទៅសិក្សាតាមប្រទេសមួយចំនួនដែលភាគីមិត្តបានផ្តល់ជូន សម្រាប់ឆ្នាំ២០១៨នេះ ដូចខាងក្រោម៖

I. **ការប្រឡងជ្រើសរើសនិស្សិតអាហារូបករណ៍សម្រាប់ឆ្នាំ២០១៨ ដែលឆ្លងកាត់ការប្រឡង**

| ល.រ | ប្រទេសផ្តល់អាហារូបករណ៍ | ចំនួនអាហារូបករណ៍តាមកម្រិត | | | | សរុប | កាលបរិច្ឆេទប្រឡង |
|---|---|---|---|---|---|---|---|
| | | ក្រ.ឧ(1) | ឧ(2) | ម(3) | ប.ប(4) | | |
| ១ | ថៃ | ៨៣២ | ២៣១ | ៣១ | ១៥ | ៣២៩ | ធ្នូ ២០១៧ |
| ២ | អង្គការសហប្រជាជាតិ | | ០៥ | | | ០៥ | ធ្នូ ២០១៧ |
| ៣ | ចិន(រដ្ឋាភិបាល) | ២៥ | ៣៥ | | | ៦០ | កុម្ភៈ ២០១៨ |
| ៤ | Teacher's Training Student (ជប៉ុន) | ០៥ | | | | ០៥ | កុម្ភៈ២០១៨ |
| ៥ | រុស្ស៊ី | | ១៥ | | | ១៥ | មីនា ២០១៨ |
| ៦ | SUSTech(ចិន) | | ១០ | | | ១០ | ឧសភា ២០១៨ |
| ៧ | ជប៉ុន(ក្រសួងអប់រំ) | ១៥ | ០៥ | ១៥ | ១៥ | ៥០ | មិថុនា ២០១៨ |
| ៨ | ចិន(Tongren University) | | ១០០ | | | ១០០ | មិថុនា ២០១៨ |
| ៩ | វៀតណាម | ២០ | ៨០ | | | ១០០ | មិថុនា ២០១៨ |
| ១០ | ចិន(ក្វាងស៊ី) | | ១០ | | | ១០ | មិថុនា ២០១៨ |
| ១១ | សាធារណរដ្ឋគូបា | | ០៤ | | | ០៤ | កក្កដា ២០១៨ |
| ១២ | ចិន(ស.ដាលី) | | ១០ | | | ១០ | កក្កដា ២០១៨ |
| ១៣ | ឡាវ | | ១០ | | | ១០ | សីហា ២០១៨ |

**កំណត់សម្គាល់**:(1)ក្រ.ឧ:ក្រោយឧត្តមសិក្សា (2)ឧ:ឧត្តមសិក្សា (3)ម:មធ្យមសិក្សាបច្ចេកទេស (4)ប.ប: បណ្តុះបណ្តាលវិជ្ជាជីវៈ។

ក.លក្ខខណ្ឌនៃការចុះឈ្មោះជាបេក្ខជន

១.បេក្ខជនទាំងពីរភេទត្រូវមានសញ្ជាតិខ្មែរ

២.មានអាយុមិនលើសពី:

- ៣៥ឆ្នាំ សម្រាប់សហព័ន្ធរុស្ស៊ី ចិន ជប៉ុន
- ៣០ឆ្នាំ សម្រាប់សាធារណៈរដ្ឋសង្គមនិយមវៀតណាម

៣.មានសញ្ញាបត្រមធ្យមសិក្សាទុតិយភូមិសម្រាប់ការប្រឡងថ្នាក់បរិញ្ញាបត្រ មានសញ្ញាបត្របរិញ្ញាបត្រសម្រាប់ការប្រឡងថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ និងសញ្ញាបត្របរិញ្ញាបត្រជាន់ខ្ពស់សម្រាប់ការប្រឡង និងជ្រើសរើសថ្នាក់បរិញ្ញាបត្រ។

៤. បេក្ខជនត្រូវចេះភាសា:

- អង់គ្លេស : សម្រាប់និស្សិតទៅសិក្សានៅប្រទេសចិន ជប៉ុន សឹង្ហបុរី ថៃ
- រុស្ស៊ី : សម្រាប់និស្សិតទៅសិក្សានៅសហព័ន្ធរុស្ស៊ី
- វៀតណាម : សម្រាប់និស្សិតទៅសិក្សានៅសាធារណៈរដ្ឋសង្គមនិយមវៀតណាម
- ថៃ : សម្រាប់និស្សិតទៅសិក្សានៅព្រះរាជាណាចក្រថៃ

៥.មានសុខភាពបរិបូរណ៍ទាំងកាយសម្បទា និងសតិបញ្ញា

ខ.វិញ្ញាសាប្រឡងរៀបចំទៅតាមកម្រិតដូចខាងក្រោម៖

១.ថ្នាក់ក្រោយឧត្តមសិក្សា( Postgraduate study )

| ល.រ | ប្រទេស | វិញ្ញាសាប្រឡង |
|---|---|---|
| ១ | ចិន | វប្បធម៌ទូទៅ ភាសាអង់គ្លេស |
| ២ | ជប៉ុន | គណិតវិទ្យា ភាសាអង់គ្លេស |
| ៣ | ថៃ | ភាសាអង់គ្លេស ភាសាថៃ |

២.ថ្នាក់បរិញ្ញាបត្រ( Undergraduate study )

| ល.រ | ប្រទេស | វិញ្ញាសាប្រឡង |
|---|---|---|
| ១ | ចិន | គណិតវិទ្យា ភាសាអង់គ្លេស |
| ២ | ជប៉ុន | គណិតវិទ្យា ភាសាអង់គ្លេស រូបវិទ្យា គីមីវិទ្យា |
| ៣ | រុស្ស៊ី | គណិតវិទ្យា វប្បធម៌ទូទៅ |
| ៤ | សឹង្ហបុរី | គណិតវិទ្យា ភាសាអង់គ្លេស |
| ៥ | ឡាវ | គណិតវិទ្យា វប្បធម៌ទូទៅ |
| ៦ | វៀតណាម | វប្បធម៌ទូទៅ គណិតវិទ្យា រូបវិទ្យា គីមីវិទ្យា |
| ៧ | ថៃ | គណិតវិទ្យា ភាសាអង់គ្លេស |



**II. ការជ្រើសរើសដោយឆ្លងកាត់គណៈកម្មាធិការជ្រើសរើសរបស់ក្រសួងអប់រំ យុវជន និងកីឡា**

អាហារូបករណ៍មួយចំនួនភាគីមិត្តកំណត់ឱ្យក្រសួងជ្រើសរើសបេក្ខជនបញ្ជូនទៅសិក្សាតែម្តងបន្ទាប់ពីបានឆ្លងកាត់គណៈកម្មការជ្រើសរើសរបស់ក្រសួងអប់រំ យុវជន និងកីឡា។ អាហារូបករណ៍ទាំងនោះរួមមាន៖

- ថ្នាក់ក្រោយឧត្តមសិក្សាទៅសិក្សានៅសាធារណរដ្ឋសង្គមនិយមវៀតណាម
- ថ្នាក់ក្រោយឧត្តមសិក្សាទៅសិក្សានៅសហព័ន្ធរុស្ស៊ី។

III. **ការជ្រើសរើសដោយភាគីមិត្ត**

ក្រសួងអប់រំ យុវជន និងកីឡានឹងធ្វើសេចក្ដីជូនដំណឹងផ្សព្វផ្សាយអំពីការផ្ដល់អាហារូបករណ៍ដែលភាគីមិត្តផ្ដល់ជូនដល់សាធារណជន សិស្ស និស្សិតកម្ពុជា និងជួយសម្របសម្រួល រៀបចំឯកសារពាក់ព័ន្ធផ្ញើជូនទៅភាគីមិត្តដែលផ្ដល់អាហារូបករណ៍ដើម្បីពិនិត្យ និង សម្រេច។ ប្រទេសដែលផ្ដល់អាហារូបករណ៍នេះមានដូចជា៖

| ល.រ | ប្រទេស | កម្រិតសិក្សា |
|---|---|---|
| ១ | ជប៉ុន( ASIAN YOUTH FELLOWSHIP ) | ថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ និង បណ្ឌិត |
| ២ | សាធារណរដ្ឋឆែក សហការជាមួយ UNESCO | ថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ |
| ៣ | ប្រទេសអាល្លឺម៉ង់( DAAD Program ) | ថ្នាក់បរិញ្ញាបត្រ បរិញ្ញាបត្រជាន់ខ្ពស់ និង បណ្ឌិត |
| ៤ | សហរដ្ឋអាមេរិក( Fulbright Program ) | ថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ |
| ៥ | សាធារណរដ្ឋឆែក | ថ្នាក់បរិញ្ញាបត្រ និងបរិញ្ញាបត្រជាន់ខ្ពស់ |
| ៦ | ប្រទេសទួរគី | ថ្នាក់បរិញ្ញាបត្រ |
| ៧ | ប្រទេសជប៉ុនJDS | ថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ |
| ៨ | នូវែលហ្សេឡង់ NZDS | |
| ៩ | កាណាដា( អាហារូបករណ៍Francophonie ) | |

ចំពោះសិស្ស និស្សិត មន្ត្រីរាជការ និងសាធារណជនទាំងអស់ដែលមានបំណងចង់បន្តការសិក្សានៅបរទេសត្រូវឈ្វេងយល់ និងអនុវត្តតាមគោលការណ៍ដូចជម្រាបជូនខាងលើ។

សម្រាប់ព័ត៌មានលម្អិតតាមប្រទេសនីមួយៗ ក្រសួងអប់រំ យុវជន និងកីឡានឹងធ្វើសេចក្ដីជូនដំណឹងទៅតាមស្ថាប័នពាក់ព័ន្ធអង្គភាពចំណុះទីស្ដីការក្រសួង មន្ទីរអប់រំ យុវជន និងកីឡារាជធានី ខេត្ត ដើម្បីធ្វើការផ្សព្វផ្សាយបន្តឱ្យបានទូលំទូលាយបន្ថែមទៀត។

អាស្រ័យហេតុនេះ សូម **ឯកឧត្តម លោកជំទាវ** មេត្តាជ្រាប និងចាត់ចែងផ្សព្វផ្សាយដល់មន្ត្រីរាជការក្រោមឱវាទឱ្យបានទូលំទូលាយតាមការគួរ។

សូម **ឯកឧត្តម លោកជំទាវ** មេត្តាទទួលនូវការរាប់អានដ៏ស្មោះស្ម័គ្រអំពីខ្ញុំ។

**អគ្គនាយក**

ប្រាក់ សំអឿន


<u>សូមទំនាក់ទំនង៖</u>

- លោក ងួន គឹមសេង
- ទូរស័ព្ទលេខ: ០១១ ៣២២ ២២៧